# ការសម្ភាសរបស់លោកយាយ ព្រំ បឿន

កៈ អ្នកធ្វើការសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកត្រូវគេសំភាសន៍ឈ្មោះ ព្រំ បឿន

កៈ ជាដំបូងសូមជំរាបសួរលោកយាយ!!

ខៈ ចាស!ចៅសាធូ!!

កៈ
ចាស!លោកយាយចាសចៅថ្ងៃនេះនឹងចៅមានឧកាសដើម្បីមកមកធ្វើការសំភាសន៍លោកយាយផ្ទាល់ចឹងចៅមានធ្វើការងារស្មោគចិត្តនៅក្នុងគំរោងរបស់ខាងសាលាBYU Hawaiនៅខាងសហរដ្ឋអាមេរិកហើយគំរោងរបស់សាលារៀនមួយនេះគឺគេចង់អោយធ្វើការសំភាសន៍នូវប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពីអាយុ៣៥ឆ្នាំឡើងអំពីពង្សប្រវត្តិរបស់គាត់អំពីបទពិសោធន៍ជីវិតរបស់គាត់តាំងពីក្មេងរហាត់មកដល់សព្វថ្ងៃនឹងដែលរហូតមកដល់សម័យឥឡូវណាលោកយាយ។

ខៈ ចាស!

កៈ
តើគាត់មានបានឆ្លងកាត់អ្វីគេខ្លះហើយគាត់នឹងមានបទពិសោធន៍អស្ចារ្យរបស់គាត់នឹងវាយ៉ាងណាខ្លះដើម្បីអោយចែកចាយអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ចឹងណាលោកយាយ។

ខៈ ចាស!ចៅ!

កៈ
ចឹងលោកយាយចៅថ្ងៃនេះសូមធ្វើការអនុញ្ញាតពីលោកយាយដើម្បីថតសំលេងរបស់លោកយាយនឹងធ្វើការសំភាសន៍របស់លោកយាយអើយអំពីពង្សប្រវត្តិនឹងបទពិសោធន៍របស់លោកយាយផ្ទាល់ចឹងតើលោកយាយនឹងអនុញ្ញាតដើម្បីអោយចៅធ្វើការសំភាសន៍លោកយាយដែលឬទេ?

ខ៖
បានតែថៅប៉ុន្តែអាត្រង់ការនិយាយនឹងយាយនិយាយទៅវាមិនបានគ្រាប់សព្វអីទេវាចាស់ហើយចឹងវាបានភ្លេចវាវង្វេតវង្វេនច្រើនណាស់ថៅ។

ក៖ ចាស!យាយ

ខ៖
គ្រាន់តែថាកាលនៅពីក្មេងនឹងយាយកំព្រាម្ដាយឪពុកនឹងតាំងពីនៅអាយុបាន៦ឆ្នាំរហូតមកនៅជាមួយនឹងជីដូនហើយដល់ពេលបានទៅនៅជាមួយនឹងជីដូននឹងក៏បានកើតជាសង្គ្រាមកាលនៅជំនាន់មានបារាំងណាហើយក៏បានរត់បែកបាក់គ្នាមកក៏បាននៅកំព្រាតែម្នាក់ឯងចឹងទៅក៏មានគ្រួសារបានមកហើយនឹងក៏បានបែកនៅជំនាន់អាពតនឹងទៀតនឹងគេបានធ្វើបាបថៅអើយអោយយាយនឹងលើកដី
ស្រះមួយៗនឹងគេបានប្រើយាយៗនឹងដូចថាគេថាវាជាកំលាំងទី១ណាដូចថាវាអត់មានកូនអត់មានថៅអីនោះទេកាលនឹងអាយុវានឹងត្រឹមតែ៤០ អី
៥០អីកាលនៅជំនាន់នឹងសុទ្ធតែជាអ្នកសែងដីហើយថៅ
កាលនៅជំនាន់អាពតនៅវាធ្វើបាបយើងអោយយើងទៅសែងដីអីនឹងពីម៉ោង៧ព្រឹកទៅចុះទៅធ្វើការហើយគេអោយយើងនឹងបានឡើងទូលវិញនឹងនៅម៉ោង១១បានគេហើយយើងសំរាកហើយហូបបាយ
ហើយចំណែកឯនៅម៉ោង១នឹងគេអោយយើងនឹងបានចុះទៅទៀតហើយពេលដែលបានស៊ីបាយហើយនឹង។

ក៖ ចាស!!

ខ៖
គេបានអោយទៅដកនឹងគេរាប់ម្នាក់១ស្លឹកៗម្នាក់ហ៎វាបានដប់ថ្លូនឯនោះចឹងបានថាវាអោយយើងនឹងដករហូតទាល់តែយប់ម៉ោង៨ទៅម៉ោង៩យប់អីនឹងមិនទាន់គ្រាប់នោះទេហើយបើថាអ្នកដែលគេដកបានគ្រាប់ហើយនឹងគេបានអោយយើងទៅសំរាកទៅហើយបើថាអ្នកដែលគេមិនទាន់បានដកគ្រាប់នឹងគេអោយយើងនឹងនៅដកនឹងទៀតរហូតទាល់តែគ្រាប់ចំនួនគេដាក់អោយ។

កៈ ចាស!លោកយាយ

ខៈ
ទាល់តែគ្រាប់ចឹងទៅបានជាគេនឹងអោយយើងនឹងបានទៅសំរាកហើយពេលព្រឹកឡើងនឹងគេបានអោយយើងនឹងទៅស្ទូងទៀតហើយគេបានវាស់អោយយើងនឹងទៅស្ទូងវាស់ក្នុង១នាក់ចឹងស្ទូង១កុងៗម្នាក់ចឹង ហើយការស្ទូងនឹងគេវាស់១២ឈើ៤ជ្រុងនឹងវាមាន១២ម៉ែត្រ។

កៈ ចាស!លោកយាយ

ខៈ
ហើយថាគេអោយស្ទូងនឹង២នាក់ក្នុង១នាក់១កុងៗម្នាក់នឹងស្ទូងរហូតដល់ម៉ោង១១នឹងមិនទាន់នឹងហើយស្រួលផង។

កៈ ចាស!

ខៈ វាមិនទាន់បានស្រួលបួលផងមកនឹងវាហើយនឹងបានជាគេអោយសំរាក

កៈ ចាស!

ខៈ
ហើយមកនឹងល្ងាចទៅនឹងត្រូវចុះទៅដកទៀតហើយពេលនឹងចុះទៅដកនឹងសំណាប់នឹងទៅធ្វើការទៀតហើយ
ពេលដែលទៅនឹងទៅដកផុតពីសំណាប់នឹងទៅគេបានមានពលកម្មថ្មីដែលគេបានហៅថាស្អីនោះទេ គេបានហៅថាពលកម្មស្អីនោះទេគេបានហៅថាដូចជាព្រឹ
ព្រឹចឹងហើយកាលនៅក្នុងជំនាន់នឹងនោះ។
គេអោយយើងនឹងត្រូវធ្វើការងារយប់ទៀតគេអោយទៅធ្វើការងារជូនរដ្ឋគេនឹងនៅក្នុង១ម៉ោងៗនឹង។

កៈ ចាស!

ខៈ គេបានរួមគ្នាទៀតហើយគេនាំគ្នាទៅជីកដីអីចឹងទៀតហើយ។

កៈ ចាស!!

ខ៖ ចឹងបានថាកាលនៅជំនាន់នឹងនោះវាបានវេទនាណាស់ចៅអើយ២ទៅ៣ជំនាន់មកនឹង។

ក៖ ចាស!ចឹងជាដំបូងនឹងចៅសូមអនុញ្ញាតសួរឈ្មោះលោកយាយសិនតើលោកយាយមានឈ្មោះអ្វីដែរ?

ខ៖ ខ្ញុំមានឈ្មោះថា ព្រំ ហឿន។

ក៖ ចាសហើយចុះឈ្មោះរបស់លោកយាយនឹងត្រូវជាមួយនឹងអត្តសញ្ញាប័ណ្ណដែលឬទេ?

ខ៖ ត្រូវតើចៅ!

ក៖ចាសលោកយាយមានឈ្មោះហៅក្រៅទេលោកយាយ?

ខ៖ ខ្ញុំនឹងគ្មានឈ្មោះហៅក្រៅនោះទេ។

ក៖ ចាស!ហើយចុះឈ្មោះរបស់លោកយាយនឹងតើនរណាគេដែរជាអ្នកដែលបានដាក់ឈ្មោះនេះអោយដល់លោកយាយ?

ខ៖ ដាក់ឈ្មោះអោយនឹងគឺយាយកាលនឹងយាយាបានដឹងនឹងត្រឹមតែយាយនឹងតែម្តង តែយាយកើតមិនបានទានគាត់បានស្លាប់ព្រោះអីកាលនឹងយាយបាននៅត្រឹមតែអាយុ៦ឆ្នាំនឹង ចឹងហើយកាលនឹងសូម្បីតែមុខម្តាយនឹងក៏មិនទាន់ស្គាល់នឹងចាំទាំងមុខរបស់ម្តាយនឹងទៀតទៅផង។

ក៖ ចាស!ចឹងលោកយាយសព្វថ្ងៃនឹងតើលោកយាយមានអាយុបានប៉ុន្មានឆ្នាំហើយ?

ខ៖ ខ្ញុំសព្វថ្ងៃនឹងខ្ញុំមានអាយុបាន៧៥ ៧៣ឆ្នាំហើយ។

ក៖ អូ!ចាស!លោកយាយ

ខ៖ ចាស!

ក៖ ហើយអើយលោកយាយមានបាននៅចាំថ្ងៃខែឆ្នាំកំណើតរបស់ខ្លួនដែរឬទេ?

ខ៖ ខ្ញុំបើឆ្នាំខ្មែរយើងនឹងខ្ញុំបានចាំតែបើថាឆ្នាំបារាំងគេនឹងខ្ញុំមិនបានចាំទេ ខ្ញុំអត់បានចាំនោះទេ។

ក៖ចាស!

ខ៖ខ្ញុំអត់ចាំទេ ចឹងហើយខ្ញុំចាំតែថាខ្ញុំបានកើតនៅក្នុងឆ្នាំរកាខែ ចេត្រ ថ្ងៃពុធដែរខ្ញុំបានកើតនឹងណា។

ក៖ ចាស!

ខ៖ ចាស!

ក៖ ហើយសព្វថ្ងៃនឹងតើលោកយាយមានទីលំនៅនៅឯណាដែល?

ខ៖ សព្វថ្ងៃនឹងមកនៅឯវត្តនឹងតែម្តង ហើយយាយបានមកនៅនឹងវត្តនឹងបាន១១ឆ្នាំហើយ។

ក៖ ចាស!

ខ៖ កាលពីដើមមកនឹងមាននៅតានៅពីនាក់លោកតាតាំងសគ្រាធវត្តនឹងតែក្រោយមកនឹងគាត់ក៏បានស្លាប់ទៅ តាខ្ញុំនឹងគាត់បានស្លាប់ចោលខ្ញុំនឹងទៅបាន១ឆ្នាំជាងហើយដែលគាត់បានស្លាប់ទៅនឹងនោះហ៎។

ក៖ ហឺ!

ខ៖ មកនៅនឹងមកនៅក្នុងវត្តលោកមកធ្វើចិត្តអីចឹងទៅ បំរើលោកអីចឹងទៅ។

ក៖ ចាស!លោកយាយ។

ខ៖ គ្រានបានពេលព្រលឹមមកនឹងគ្រាន់បានជូតតុរៀបចំអីសំរាប់នឹងប្រគេនព្រះសង្ឃសំរាប់ចង្ហាន់ចឹងទៅ។

ក៖ ចាស!!

ខ៖ គ្មានការងារអីនោះទេ អើលោកមិនទៅអោយយើងនឹងទៅធ្វើការងារធន់នោះទេ ចាស់ៗហើយនឹងចឹងហើយបានតែធ្វើនៅនឹងវត្តនឹងទៅគ្រាន់បានចឹងមិនទៅសង្ឃឹមអីនោះទេ ចៅអើយសព្វថ្ងៃនឹងនោះ។

ក៖ ចាសចុះ!

ខ៖ នរណាគេស្លាប់អីនៅនឹងវត្តនឹងនោះ។

ក៖ លោកយាយមានស្រុកកំណើតនៅឯណាដែល?

ខ៖ ខ្ញុំមានស្រុកកំណើតនៅឯស្រុកព្រៃវែងឯណោះចៅ នៅក្បែរនឹងវៀតណាមខាងត្បូងនឹងដែលកាលពីដើមមកឡើយនឹងគេបានហៅថាជាស្រុកព្រះស្ដេច ភូមិព្រះស្ដេច ខេត្តព្រៃវែង។

ក៖ ចាស!

ខ៖ នឹង!

ក៖ ហើយសំរាប់នឹងទីលំនៅសព្វថ្ងៃនឹងលោកយាយមានទីលំនៅឯណាដែលលោកយាយ?

ខ៖ វត្តនឹងគេហៅថាវត្តចិនដំដែកកាលពីមុនមកនឹងតែដល់ពេលឥឡូវនឹងបែរឈ្មោះមកនឹង។

ក៖ ចាស! ចាស! ហើយចំពោះទីតាំងវិញតើលោកយាយមានបានដឹងដែរឬទេថាវានៅទីតាំងនៅកន្លែងណាដែលដូចជាខណ្ឌ័ស្រុកស្កាត់អីនឹង?

ខ៖ សង្កាត់នឹងសង្កាត់ស្រះចក ខណ្ឌ័នឹងខណ្ឌ័ដូនពេញហើយនៅត្រង់នឹង។

ក៖ ចាស!លោកយាយរាជធានីភ្នំពេញ។ចាសហើយលោកយាយសព្វថ្ងៃនឹងតើលោកយាយមានកូនចៅប៉ុន្មានហើយលោកយាយ?

ខ៖ កូនចៅនឹងវាបែកខ្ញែងគ្នាអស់ចឹងទៅវាមិនដឹងថាទៅច្រកណាមកច្រកណានោះទេ អត់ដឹងទេ ខ្ញុំមានកូនចៅនឹង៣នាក់ដែលគេរកស៊ីនឹងណា។

ក៖ ចាសលោកយាយសព្វថ្ងៃនឹងលោកយាយមានកូនចៅសរុបបានប៉ុន្មាននាក់ដែរ?

ខ៖ កូនចៅសរុបនឹងមានចំនួន៨នាក់ដែរ។

ក៖ អូ!

ខ៖ តែត្រូវបានបែកខ្ញែកគ្នាអស់ហើយ។

ក៖ អូ!

ខ៖ អានឹងវាជាផលបុណ្យរបស់យើង។

ក៖ ចាស!

ខ៖ នឹងហើយ។

ក៖ ចាស!ហើយចឹងកូនចៅរបស់លោកយាយមានឈ្មោះអ្វីខ្លះដែរទៅលោកយាយ?

ខ៖ ឈ្មោះរបស់មីបងនឹងគេមានឈ្មោះប៉ុន្តែនឹងយើងគិតែសំរាប់អ្នកដែលគេនៅនឹងទេអើណែ មានសុន លីមួយ ជាមួយ ស្រីនាងមួយដែលជាកូនពៅនឹងណាមានកូនចំនួន៣នាក់នឹង។

ក៖
ចាស!លោកយាយមានកូនចំនួន៣នាក់នឹងហើយចឹងតើលោកយាយមានកូនស្រីប៉ុន្មាននាក់ ហើយកូនប្រុសមានប៉ុន្មាននាក់ដែរ?

ខ៖ យាយមានកូនស្រី១នាក់នឹងកូនប្រុស២នាក់។

ក៖ចាស!

ខ៖ ដែលសព្វថ្ងៃនឹងគាត់នៅឯភ្នំពេញនឹង។

ក៖ ចាស់!

ខ៖ គេមានមុខរបរនឹងធ្វើជាជាងមាស ធ្វើជាជាងម៉ូតូ ។

ក៖ចាស!

ខ៖ ហើយក៏មានធ្វើជាជាងម៉ូតូអីសំរាប់ប៉េះយកទៅធ្វើអីនឹង។

ក៖ ចាស!

ខ៖
គេនឹងចេះទៅរកស៊ីទៅមុខរបរនឹងហើយចំណែកឯមីមួយនោះនឹងដែលគេមានទីលំនៅនៅឯបុរីសន្តិភាពនឹង ដែលគេបាននៅក្នុងបុរីសន្តិភាពទី២ក្នុងបុរីនៅឯចោមចៅនឹង
ដែលគេបានឡើងទៅខាងត្បូងនឹង។

ក៖ ចាស!

ខ៖
ហើយមួយទៀតនឹងគេបាននៅលក់គេមានផ្ទះជួលគេនឹងនៅនឹងក្បែរវត្តនឹងដែលនឹងដែលគេបានលក់ទឹកកកទឹកអីនឹងតាមរទេះគោទៅណាកូនអើយគេបានលក់លត
លក់អីនឹងតាមផ្លូវលក់មីឆាអីនឹងនៅតាមផ្លូវ គេមិនជាអ្នកមានអីនោះទេ។

(សំលេងធ្លាក់ចាន)

ក៖ ចាស!លោកយាយហើយអើយ
ទាក់ទងជាមួយនឹងកូនចៅរបស់លោកយាយទាំង៦នាក់ទៀតលោកយាយដែលគេបានស្លាប់នៅក្នុងសម័យពតនឹងតើលោកយាយបានចាំឈ្មោះរបស់ពួកគាត់ដែលឬទេ?

ខ៖ ចាំតើកូនបងគេនឹងគេបានឈ្មោះថា រ៉ែន
ហើយរ៉ែនហើយមកបុប្ផាហើយនឹងវាមានតែប៉ុណ្ណឹងទេចាស។

ក៖
ចាស!ទៅអីលោកយាយកាលនៅក្នុងសម័យមានមូលហេតុអ្វីដែលបណ្តាលអោយលោកយាយដឹងថាពួកគាត់បានស្លាប់នៅក្នុងជំនាន់ពពតតើលោកយាយបានមើលឃើញនឹងភ្នែកឬក៏យ៉ាងណាដែរ?

ខ៖ កាលនឹងវាបានបាត់ខ្លួនអស់ចឹងទៅវាមិនបានដឹងថាគេយកគាត់ទៅណាទៅណានោះទេ។

កៈ
អូ!ចឹងកាលនៅក្នុងសម័យនឹងគេបានជំលៀសគាត់ហើយគេបានជំលៀសគាត់នឹងទៅទាំងគ្រួសារឬក៏យ៉ាងណាដែរកាលនឹង?

ខៈ កាលនឹងគេបានចំលៀសទៅនឹងបានបែកគ្នានឹងគ្រួសារទៅខ្លះទៅកាលនឹង។

កៈ អូ!

ខៈ ហើយខ្លះចឹងទៅក៏បានបាត់គ្រួសារចឹងទៅណា។

កៈ ហឺ!

ខៈ កាលនឹងកាលជំនាន់នឹងវាវាងពិបាកដែរនឹង ។

កៈ ចាស!

ខៈ កាលនឹងមានរត់ មានដក លួនផងអីចឹងការនឹង។

កៈ អូ!កាលនឹងគេបានជំលៀសលោកយាយទៅណាដែល?

ខៈ
កាលនឹងគេជំលៀសយាយនឹងណាវាវេទនាណាស់ណាចៅគេបានធ្វើការជំលៀសយាយនឹង
នៅអីស្រុកព្រះស្ដេចនឹងគេបានធ្វើការជំលៀសទៅអី
អីមានពោធិសាត់អីណានោះទេយាយអើយកាលនឹងមានភ្នំខៀវណានោះទេ។
នៅឯស្រុករាជណាណំ គេបានធ្វើការជំលៀសនឹងទៅឯខាងនឹងរួចដល់

កៈ ចាស!

ខៈ
ហើយទៅក៏បាននាំគ្នាមកវិញនឹងក៏បានបែកបាក់គ្នាចឹងទៅកាលនឹងហើយពេលដែលបានរួចអស់ចឹងទៅក៏មិនបានដឹងថាគេបានបញ្ជូនយើងនឹងអោយទៅកន្លែងណាកន្លែងណានោះទេអត់បានដឹង។

កៈ ហឺ!

ខ៖ បែកគ្នាអស់ហើយ

ក៖
ហ៊ីចឹងហើយនឹងបានជាធ្វើអោយម៉ាបានបែកបាក់គ្នាព្រមទាំងកូនអីនឹងព្រោះអីកាលនឹងគេបានអោយយើងនៅជាមួយនឹងគ្នានោះទេ។

ខ៖ នឹងហើយ

ក៖ ចាស!ហើយគេបានប្រើលោកយាយធ្វើអ្វីគេខ្លះកាលនៅក្នុងសម័យនឹង?

ខ៖អូសម័យនឹងគេបានប្រើនឹងវាដូចអ្វីដែលខ្ញុំបាននិយាយមុននឹងណាចៅ។

ក៖ ចាស!

ខ៖
វាប្រើយើងនឹងអោយធ្វើការងារសព្វមុខតាំងពីលើកដីដកស្ទូងអីសព្វមុខទាំងអស់ហើយការងារនោះ។

ក៖ចាស!!

ខ៖
ហើយទៅមានគេអោយទៅដាំជំឡូងទៅដាំអីចឹងទៅទៅដាំជំឡូងនឹងទៅហើយមានពេលខ្លះចឹងទៅក៏បានទៅចាំធ្វើចំការគេចឹងទៅគេបានអោយទៅចាំចំការគេដើម្បីអោយយើងនឹងទៅយាមចំការគេចំការអីគេចឹងទៅដែលគេបានជំលៀសយើងទៅនឹង។

ក៖ គេបានអោយយើងនឹងបានធ្វើច្រើនមុខណាស់កាលនឹង។

ខ៖
នឹងហើយគេបានអោយយើងធ្វើការងារច្រើនមុខណាស់កាលនឹងនោះមានគេបានអោយយើងនឹងទៅជំលៀស។

ក៖ ចាស!

ខ៖
គេបានអោយយើងនឹងទៅជំលៀសជំអីនឹងដែលយើងវាមិនដែលបានធ្លាប់បានដឹងនឹងចេះធ្វើកាលពីមុនមក។

ក៖ ចាស!

ខ៖
កាលនឹងគេបានទៅស្រុកផ្សេងអស់នឹងដែលយើងមិនដែលនឹងបានធ្លាប់ស្គាល់ពីមុនមកនឹង។

ក៖
ចាស!ហើយដល់ពេលនឹងតើលោកយាយបានធ្វើការដូចថាប៉ុន្មានម៉ោងដែលនៅក្នុង១ថ្ងៃ?ហើយគេបានអោយអាហារដល់យាយពិសារបានប៉ុន្មានពេលដែរ?

ខ៖
បាយនឹងគេបានអោយយើងបាន២ពេលដែលពេលព្រឹកនឹងគឺអត់បានបាយហូបនោះទេទាល់តែពេលម៉ោង១១នឹងបានគេអោយបាយយើងសំរាប់ហូប
គេបានអោយយើងសំរាប់យកមកហូបហើយគេបានអោយយើងនឹងទៅធ្វើការអីអោយវាចឹងទៅដល់ពេលដល់ម៉ោង១១នឹងបានឡើងមកសំរាកមក
ហើយក៏បានជូនគេនឹងអោយបាយសំរាប់មកហូបមកហើយជូននឹងគេបានអោយបបរក្នុង១នាក់នឹងគេបានអោយបបរ១នាក់បាន១តំឡោកដូងហើយនឹងព្រោះអីគេបានធ្វើអាតំឡោកដូងគេនឹងគេបានយកតំឡោកដូងនឹងបានមកធ្វើជាវែក
ហើយគេបានយកវាដើម្បីមកដូសបបរហើយគេបានដូសអោយ១នាក់បាន១វែកៗគេនឹងបបរនឹងមានជាតិអង្កអីបានប៉ុន្មាននោះទេ។

ក៖ ចាស!!

ខ៖
ទឹកឡើងលឺជ្រួចៗដែលគេបានវាលចាក់អោយនឹងហើយទៅគេមានកាន់របស់អីចឹងណាដូចជាបានត្រីងៀត គេនឹងក៏
ហើយមានក្តាមដុតក្តាមអីចឹងទៅបើបានឹងគេបានចាប់ពិន័យយើងនឹងគេបានយកទៅបោះចោលអស់ហើយ។

ក៖ ចាស!ត្រូវលោកយាយចាស

ខ៖
ហើយទៅបបរវានឹងស្លជាមួយនឹងអាសំឡប្រលិតហើយនឹងហើយបើមើលទៅទឹកវានឹងឡើងព ណ៌ខ្មៅហើយក៏អោយហូប។គេស្លនឹងមានសំឡម្ជូរព្រលិតសាច់ក្របីក៏មាន។

ក៖ អូ!បានសាច់ក្របី កាលនឹងមានបានសាច់ក្របីទៀតកាលនឹង។

ខ៖ អើ
មានសាច់ក្របីដែលគេបានអោយទៅសហាករគេនឹងចិញ្ចឹមហើយវាមានងាប់អីចឹងណាចឹងហើ យគេក៏បានយកវាទៅស្លអីចឹងទៅកាលនឹងហើយយើងនឹងអត់បានហូបអីចឹងហើយពេលគេដា ក់អោយហូបនឹងខ្ញុំមិនបានហូបទេសាច់ក្របីនោះ
ហើយក៏បានទៅអោយគេដូជាអំបិលសំរាប់ហូបវិញ
ហើយពេលដែលទៅសុំអំបិលគេហូបនឹងគេថាយើងនឹង គេហើយយើងនឹងថាក្រាស់អីម៉េចទេ ស្អីទេកាលនឹងគេបានហៅថាម៉េចថាកាលនឹងខ្ញុំវាមិនបានចាំដែលនាងអើយ។

ក៖ អូ!

ខ៖ កាលនឹងគេបានថាអោយយើងនឹងវានៅក្រាស់ណាស់
មិនទៅតាមគេហើយយើងនឹងមិនបានទៅតាមគេ គេថាអោយយើងនឹងរើកអីចឹង
ព្រោះអីមិនបានហូបសំឡ
កាលនឹងខ្ញុំបានប្រាប់គេថាខ្ញុំមិនហូបទេសាច់ក្របីសាច់អីនឹងខ្ញុំមិនដែលហូបសោះ។
គេបានថាអោយយើងថាយើងនិងអីទេពាក្យគេនឹងដូចជាក្រាស់អីទេនឹងវាបានភ្លេចទៅហើយ។

ក៖ ចាស !

ខ៖ យើងហូប

ក៖
អូចឹងដោយសារតែកាលនឹងលោកយាយមិនបានហូបគ្រាប់គ្រាន់អីចឹងលោកយាយកាលនឹង

ខ៖ អូយកាលនឹងវាមិនបានហូបគ្រាប់គ្រាន់នោះទេអាថៅអើយ

ក៖ ហើយចឹងលោកយាយមានបានធ្លាប់ឈឺដែរឬទេ?

ខ៖
អាឈឺនឹងវាបានឈឺណាស់ទៅហើយប៉ុនតែវាមានថ្នាំគេចឹងទៅយើងនឹងក៏ស្គាល់ថ្នាំអីចឹងទៅគេក៏បានអោយយកមកអោយយើងនឹងបានហូបអាប្រភេទថ្នាំនាយអាយគេនឹងគេបានអោយយើងនឹងដើម្បីយកមកសំរាប់នឹងហូបវាមានរាងដូចទៅនឹងអាស្អីណែលដូចស្អី
ដូចជាអាជំឡូងឈើយើងនឹងដែលគេបានបុកយកទៅដាក់ដាំនឹងដែលយកទៅស្លធ្វើជាស្អីគេនឹង
គេលុនវានឹងគេបានអោយយើងលេបអីចឹងទៅសំរាប់នឹងផ្សំវាបានអោយផ្សំៗទៅអាថ្នាំពេទ្យគេនឹង។
បើគេហៅនេះនឹងគេបានហៅអាថ្នាំអាចម៍ទន្សោយគេនឹងគេបានអោយយើងនឹងទៅពិន័យអោយគេទៀតណំព្រោះអីកាលនឹងគេបានហៅអោយយើងនឹងវាខុសចឹងហើយគេបានអោយយើងនឹងទៅកែលវិញ
ព្រោះអីថ្នាំនឹងវាជាប្រភេទថ្នាំកែលរោគរបស់យើង(ថ្នាំសំរាប់យកមកព្យាបាលជំងឺ)ព្រោះអីបើកាលនឹងរាងវាមូលៗខ្មៅៗដូចអាចម៍ទន្សាយចឹងហើយគេបានអោយយើងនឹងលេបចឹង។
ហើយពេលដែលគេបានអោយយើងនឹងបានទៅស្ទូងហើយជុំគ្នាថាគេបានអោយអីយើងហូបគេថាថ្នាំអីគ្រាន់បានគ្រាន់បើជាក្តៅអីចឹងកាលនឹងព្រោះអីកាលនឹងវាមិនគ្រាប់ដូចជាអាចម៍ទន្សាយនោះនិយាយចឹងអីនឹងក៏គេយកទោសយើងដែរ។

ក៖ ហឺសៗ

ខ៖
ព្រោះអីយើងបានមើលងាយដល់គេវាមិនបាកណាស់នាងអើយបើនិយាយពីរឿងជំនាន់អាពតនឹងវាមិនបានណាស់វាពិបាកតាំងពីការហូបចុកឡើងតាំងពីកាលធ្វើការគេបានដាក់វិន័យគេនឹងអោយយើងយ៉ាងតឹងតែង
ហើយគេថាអោយយើងនឹងពេលដែលយើងនឹងទៅវាមិនទាន់ម៉ោងគេចឹងហើយគេពិន័យយើងអោយទៅឈរនៅកណ្តាលហាលថ្ងៃអី។
វាសព្វបែបសព្វគ្រាប់ណាស់ហើយកាលនៅជំនាន់នឹងនោះតែវាគ្រាន់បើថាកាលនឹងនៅជំនាន់

នឹងវាអត់មានចោរនោះទេ គ្មាននរណាគេលួចរបស់អាណានោះទេគ្មានការលួចនោះទេ កាលនឹងលួចគ្នានឹងវាមិនបាននោះទេ។

ក៖ ចាស!ត្រូវហើយកាលនឹងគិតបានត្រឹមតែខំធ្វើការ។

ខ៖ គេនាំគ្នាគិតតែខំប្រឹងធ្វើការ
យាយនឹកឃើញជំនាន់នឹងយាយមិនចង់នឹងនិយាយនោះទេយាយចង់តែទឹកភ្នែកទេ។

ក៖
អូយលោកយាយចៅសូមទោសផងដែលធ្វើការសំភាសន៍លោកយាយទាក់ទងនឹងប្រវត្តិមួយនឹងប៉ុន្តែវានឹងធ្វើអោយអឺ
កូនចៅជំនាន់ក្រោយទៀតគេបានដឹងព្រោះអីគេបានស្តាប់ពាក្យសំដីពិត។

ខ៖ ចាសៗ!

ក៖
ព្រោះមានសំលេងរបស់លោកយាយដែលនឹងបានហើយក៏សង្ឃឹមដែលថាពេលដែលលោកយាយនិយាយវាចេញមកនឹងវាបានធ្វើអោយលោកយាយធូបានខ្លះដែល។

ក៖ ចាស!

ខ៖ ព្រោះអីការសំភាសន៍មួយនឹងគេចង់អោយលោកយាយនិយាយរឿងរ៉ាវរបស់លោកយាយនឹងពិតចឹងទៅវានឹងអាចជួយដល់អារម្មណ៏នឹងផ្លូវចិត្តរបស់លោកយាយបានខ្លះដែរដោយសារតែកាលនឹងអឺការសំភាសន៍នឹងដូចជាមានប្រវត្តិប្រជាជនកម្ពុជាមួយចំនួននឹងគាត់មិនទាន់នោះទេ

ក៖ នឹងហើយ

ខ៖ ដូចជាដូចនៅក្នុងជំនាន់របស់ខ្ញុំនឹងមិនបាននឹងទាន់កាលនៅក្នុងសម័យនោះសោះ

ក៖ នឹងហើយ

ខ៖
ចឹងហើយបានជាលោកយាយជាអ្នកដែលបានកើតទាន់កាលនៅជំនាន់នឹងចឹងហើយលោកយាយគឺជាអ្នកកាលពីជំនាន់មុនដែលលោកយាយមានប្រវត្តិរបស់ខ្លួនហើយបានធ្វើការតស៊ូចិញ្ចឹមកូនមកដល់ជំនាន់នេះចឹងហើយលោកយាយជាស្រីមួយដល់អស្ចារ្យមែនទែនចឹងហើយបានដូចជាចិញ្ចឹមកូនទោះបីជាមានការលំបាកអីតាំងពីបានដាច់ជំនាន់អាពតមកណាលោកយាយ។

ក៖ ហើសៗៗ

ខ៖
ចឹងហើយតើលោកយាយពេលដែលបានដាច់ជំនាន់អាពតមកហើយនឹងតើលោកយាយបានធ្វើការចីញ្ចឹមកូនពីមុនមកនឹងយ៉ាងណាដែរ?ហើយលោកយាយជួបនឹងការលំបាកអ្វីខ្លះដែរទៅលោកយាយ?

ក៖
វាឆ្លងកាត់នឹងដូចថាពេលដែលបានដាច់អាពតមកនឹងវាបាននៅតាមផ្លូវនឹងវាបាននៅសល់ស្រូវនឹងនៅតាមផ្លូវមកខ្លះនឹងក៏បានជ្រូតវាមិនទាន់អស់នោះទេកាលនឹងក៏បានដើរទៅប្រមូលផលទាំងម៉ែនឹងទាំងកូ
នតាំងគេតាំងឯងអីនឹងទាំងអស់នឹងណាវាបានដើរជ្រូតនឹងវាពេសនឹងនៅកន្លែងនេះបន្តិចទៅនៅនោះបន្តិចទៅហើយបានធ្វើការសន្សំទៅក៏បានមកសំរាប់យកមកអោយកូនអីនឹងបានហូបមកអីនឹងហើយកាលនឹងមានពេលខ្លះទៅមានបានហូបដូចជាគល់ចេក
ហូបអាដែងណោហូបគល់ដើមល្ហុងអីទៀតណ៎
កាលនៅក្នុងជំនាន់នឹងកាលដែលបានបែកភ្លាមៗនឹងវាមិនទាន់បានរកអីសំរាប់យកមកហូបហើយចឹងដូចថាបានទៅកាប់គល់ចេក គល់អីនឹងសំរាប់យកមកចំហុយយកមកសំរាប់ហូបហើយធ្វើការចំហុយអីនឹងយកទៅអោយកូននឹងបានហូបជាមួយនឹងអង្កដែលយើងបានទៅរកស្រូវមកបន្តិចបន្ទួចមកនឹងដូចថាគេដូចជាឯងហើយឯងនឹងដូចគេចឹងដែរនឹង
កាលនឹងវាមិនមែនតែយើងនឹងទេវាបានវេទនានឹងមានគេមានយើងម៉ាលជំនាន់នឹងនោះហើយកាលនឹងបានពូជបានអីចឹងទៅយើងបានស្រូវនឹងបាន១កូនល្អីតូចៗនឹងយកទៅសាបហើយក៏បានជាពូជនឹងទៅទាំងគេនឹងទាំងឯងនឹងសំរាប់យកធ្វើជាពូជនឹងសាបទៅ

បានជាអង្កមានវិញមករហូតនឹងទៅ (ដកដង្ហើមសឹត) មួយជំនាន់នឹងតែក្រោយមកនឹងជាជំនាន់សម្តេចនឹងបានយើងរាងបានធូធារចឹងទៅ។

ក៖ ហឺ!

ខ៖ ប៉ុន្តែទំរាំតែបានចូលមកដល់ជំនាន់នឹងនោះវាបានវេទនាណាស់កាលពីជំនាន់មុននឹងនោះតាំងពីហូបចុកអីនឹងកាលនឹង។

ក៖ ចុះកាលពីបានដាច់ជំនាន់អាពតនឹងមកតើលោកយាយមានបានប្រកបមុខរបស់អ្វីខ្លះសំរាប់នឹងធ្វើការចិញ្ចឹមជីវិតបន្តៗរហូតមកណាលោកយាយ?

ខ៖ ខ្ញុំបានធ្វើស្រែតែមួយនឹងគត់នឹងណានាង។

ក៖ ចាស!លោកយាយមានតែធ្វើស្រែទេ។

ខ៖ មានតែធ្វើស្រែនឹងទេតាំងពីបានដាច់មកនឹងហើយណាមានបានធ្វើស្រែនឹងណា

ក៖ ចាស!

ខ៖ មានបានតែធ្វើស្រែនឹងឯង។

ក៖ ហើយចឹងកាលនឹងលោកយាយអាចរកបានប៉ុន្មានដែលនៅក្នុង១ថ្ងៃ?

ខ៖ កំរៃនឹងបានធ្វើនឹងគ្រាន់តែបានធ្វើសំរាប់តែបានធ្វើគ្រាន់តែបាននឹងធ្វើការដោះដូរសំរាប់នឹងម្ហូបនឹងទេ

ក៖ ចាស!

ខ៖ ហើយយើងនឹងបានធ្វើការដោះដូរនឹងបានត្រឹមតែបានលុយបានកាក់អីនឹង។

ក៖ ហឺ!

ខ៖ ហើយបើថារឿងស្រូវអីនឹងបានធ្វើនឹងវាមិនបានទៅលក់ដូរអីនោះទេ។

ក៖ ចាស!!

ខ៖ យើងបានធ្វើនឹងគ្រាន់តែបាននឹងការដោះដូរអីនឹងទៅសំរាប់នឹងចិញ្ចឹមកូនណា។

ក៖ ចាស!!

ខ៖ វាបានមកនឹងតែបន្តិចបន្តួចចឹងទៅ។

ក៖
ចាស!ចឹងចំណូលរបស់លោកយាយកាលនៅជំនាន់នឹងកាលនឹងគ្រាន់តែដើម្បីនឹងគ្រាន់តែសំរាប់ការចំណាយទៅលើការបរិភោគអីចឹងទេនឹងដើម្បីនឹងធ្វើការចិញ្ចឹមកូនអីនឹងអត់មានបាននៅសល់អីនោះទេណ៎លោកយាយ?

ខ៖ គ្មានបាននៅសល់អីនោះទេចៅអើយ។

ក៖ ចាស!

ខ៖ នឹង!

ក៖
ប៉ុន្តែនៅក្នុងសម័យរបស់លោកយាយតើលោកយាយមានបាននឹងឆ្លងកាត់នៅជំនាន់អ្វីគេខ្លះ?

ខ៖ ជំនាន់ដែលយាយបានឆ្លងកាត់មកនឹងមានតាំងពីជំនាន់បារាំង ជប៉ុន
ដែលពេលនឹងខ្ញុំបាននៅវាងតូចនឹងហើយចឹងវាមិនទាន់បានទៅដឹងអីបានប៉ុន្មាននោះទេគ្រាន់តែបានដឹង ព្រោះអីនៅវ័យនឹងវានៅវាងខ្ចីណាស់។
កាលពីជំនាន់បារាំងនឹងមកខ្ញុំបានរត់គេបានដេញចាប់ដេញអីនឹងគេបានហៅចាប់ម៉េចគេនឹងកាលនៅជំនាន់បារាំងនឹងគេបានហៅហើយចាប់ម៉េចគេទេគេហៅម៉េចទេកាលនៅក្នុងជំនាន់បារាំងនោះ
អូដូចជាលោកឪពុកខ្ញុំនឹងគេបានចាប់គាត់នៅជំនាន់បារាំងនឹងគេបានចាប់គាត់ហើយយកគាត់នឹងទៅសំលាប់ចោលនឹងកាលនឹង។ កាលនឹងឪពុករបស់ខ្ញុំនឹងណា។

ក៖ ចាស!

ខ៖ ហើយម្តាយរបស់ខ្ញុំនឹងពេលបានទៅតាមនឹងក៏គេបានសំលាប់គេចោល គេថារកចាប់អ្នកដែលអត់មានអាកាតខ្មៅគេនឹងហើយយើងកាលនឹងអត់មានអាកាតខ្មៅនឹងគេនឹង ហើយចឹងគេបានសំលាប់ចោលហើយកាលនៅជំនាន់បារាំងនឹងនោះគេយកទៅហើយហើយចឹងបានបាត់ទាំងអស់ចឹងទៅព្រោះអីគេបានដឹងថាគេយកគាត់ទៅខាងណា។

ក៖ ហឺ!

ខ៖ កាលនឹងគេបានយកឪពុករបស់ខ្ញុំនឹងទៅមុនហើយបន្ទាប់មកនឹងគេបានយកម្តាយរបស់ខ្ញុំនឹងទៅតាមក្រោយ។

ក៖ ម្តាយលោកឪពុករបស់លោកយាយមានឈ្មោះអ្វីដែរលោកយាយ?

ខ៖ លោកឪពុកខ្ញុំនឹងមានឈ្មោះថាព្រំ បុត ហើយចំណែកម្តាយវិញមានឈ្មោះថា កៅ ហិន។

ក៖ ចាស !ហើយចុះស្វាមីរបស់លោកយាយគាត់មានឈ្មោះអ្វីដែរ?

ខ៖ គាត់មានឈ្មោះថា ថើ បន ។

ក៖ ចាសហើយកាលនឹងលោកយាយបានរៀបការជាមួយនឹងលោកតានឹងកាលនឹងលោកយាយនឹងលោកតាបានស្រុលាញ់គ្នាឬក៏ឪពុកម្តាយគាត់ជាអ្នកដែលបានរៀបចំអោយ?

ខ៖ កាលនឹងឪពុកម្តាយនឹងគាត់ជាអ្នករៀបចំអោយដូចថាពេលនឹងឪពុកម្តាយនឹងបានទៅបួសនៅឯវត្ត គាត់បានបួសហើយទៅគាត់បានធ្វើជាសង្កាចវត្តទៅ តែពេលដល់ជំនាន់លុនណល់ នឹងអាពតនឹងបានគេបានចាប់គេផ្សឹកចឹងទៅ ហើយតាំងពីគេផ្សឹកតាំងពីពេលនឹងមកនឹងវាយូរហើយគាត់៣០ឆ្នាំជាងហើយ។

ក៖ ចាស!!

ខ៖ គាត់នឹងបានយូរហើយគាត់បាន៣០ទៅ៥០ឆ្នាំហើយគាត់បានមានវ័យចាស់ជាងខ្ញុំនឹង។

ក៖ ហើយលោកយាយបានរៀបការនៅក្នុងឆ្នាំណាដែរ?

ខ៖ ហែសកាលនឹងយាយមិនបាននៅចាំទេកូន។

ក៖
ចឹងកាលនឹងលោកយាយបានការនឹងនៅក្នុងជំនាន់អាពតឬក៏នៅក្នុងជំនាន់ណាដែលលោកយាយឬក៏លោកយាយបានការនៅមុនអាពត?

ខ៖ ប្រហែលជាបានការនឹងនៅមុនអាពត នៅមុន នៅមុនអាពត។

ក៖ ចាស!ហើយបើមុនអាពតនឹងតើលោកយាយមានកូននៅក្នុងជំនាន់អាពតដែលឬទេ?

ខ៖ ជំនាន់អាពតនឹងមានកូនបាន១នាក់
កូននឹងក៏វាបានបាត់បង់ជីវិតទៅកាលនឹងវាមិនបានរស់នៅទេ។

ក៖ អូ!ចឹងកាលនឹងតើកូននឹងមានអាយុបានប៉ុន្មានហើយ?

ខ៖ កាលនឹងកូនមួយនាក់នឹងមានអាយុបានដូច៣០ជាងហើយ។

ក៖ អូយ…កាលជំនាន់នឹងគាត់មានអាយុបាន៣០ជាងហើយ។

ខ៖ ចាស!

ក៖ ហើយកាលនៅក្នុងជំនាន់នឹងតើលោកតាទឹមតែបានកូន១នាក់នឹងទេ?

ខ៖ អត់ទេមានមុនៗ១
កាលនៅមុនអាពតនឹងយើងមានមុនៗមកនឹងហើយកាលនៅមុនអាពតណា។

ក៖ អូ!

ខ៖ តែថាមកដល់ក្នុងអាពតនឹងមានកូនតែមួយនាក់នឹងទេ។

កៈ
ចាស!ហើយដល់ពេលដែលបានដាច់អាពតនឹងមកនឹងតើលោកយាយមានកូនចំនួនបានប៉ុន្នានដែរលោកយាយ?

ខៈ
ពេលដែលបានដាច់អាពតហើយនឹងដែលបានដាច់អាពតមកហើយនឹងបានកូនចំនួន២នាក់ទៀត
នឹងកាលដែលបានបែកពីអាពតនឹងហើយនឹងយើងបានបែកគ្នាហើយគ្រួសារនឹងគាត់ក៏គ្មានបានកូនចៅអីទៀតដែលនឹងព្រោះអីយើងនឹងវាអាយុច្រើនដែលហើយណាស់។

កៈ ហឺ !ចាស!

ខៈ បែកអស់ហើយ សព្វថ្ងៃនឹងបាននៅតែនាក់នឹងទេដែលបាននៅក្នុងភ្នំពេញនឹង។

កៈ
ចាស!ហើយនៅក្នុងសម័យពពតនឹងតើលោកយាយមានបានចង់នឹងចាំអ្វីជាងគេដែលធ្វើអោយលោកយាយមិនអាចនឹងបំភ្លេចបានសោះឡើយនៅក្នុងជីវិតរបស់លោកយាយ?

ខៈ
កាលនៅក្នុងជំនាន់អាពតនឹងពេលដែលមិនអាចនឹងបំភ្លេចបានសោះឡើយនឹងគឺការងារនឹងការហូបចុកនឹងណា។

កៈ ចាស!!

ខៈ ដូចថាពេលនឹងវាលំបាកវេទនាដូចថាមានកូនចៅអីនឹងឈឺហើយនៅកន្លែងកងធំអីគេនឹងគេមិនបានអោយយើងនឹងទៅសួរនាំអីគេទេកាលនឹងគេមិនបានទៅសួរពេទ្យនោះទេដូចជាមានម្ដាយអីឈឺនៅផ្ទះនឹងក៏កូនមិនបានហ៊ាននឹងមកសួរបានដែរ។
ថាគេនឹងពេលនឹងវាមានពេទ្យហើយនឹងតែមិនបានសួរនាំអីនោះទេ
អានឹងវាវេទនានឹងថាវាចង់ចាំថាវាពិបាក
វាឈឺចាប់នឹងវាមិនអាចនឹងសួរគេមិនបានហើយនឹងការហូបចុកអីនឹង
ការហូបចុកអីនឹងការងារអីនឹងតែម្ដង។

កៈ ហឺ!!

ខៈ ហើយចំណែកឯបបរនឹងវាបានចែកអោយហូបមិនបានទៅឆ្អែកអី កាលនឹងរបបនឹង។

កៈ ចាស!
ចាស!លោកយាយហើយដល់ពេលចឹងនៅក្នុងជីវិតរបស់លោកយាយមានការលំបាកជាច្រើនណាលោកយាយណ់?

ខៈ ចាស!

កៈ
ចឹងតើការលំបាកទាំងអស់នឹងតើមានចំណុចណាខ្លះដែរធ្វើអោយលោកយាយចង់ចាំនឹងមិនអាចនឹងបំភ្លេចបានដែរបានយាយ?

ខៈ ដូចថានៅក្នុងជំនាន់ ដែងថាខ្លាំងបំផុតនឹងគឺនៅក្នុងជំនាន់អាពតណាកូន ខ្ញុំបានចង់ចាំជាងគេ ។ ដូចថាកាលពីមុនមកនឹងដូចថាវារាងធម្មតានោះទេ កាលនៅក្នុងជំនាន់បារាំអីនឹងដូចថាយើងបានរត់ចុះរត់ឡើងអីនឹងហើយទៅវាក៏បានទៅជារស់សុខស្រួលវិញតែថាពេលដែលបានមកដល់នៅក្នុងសម័យជំនាន់អាពតនឹងដូចថាវាលំបាកណាស់វាបានផ្តាច់ត្រឹមនឹងតែម្តងកូនចៅអីនឹងវាបានផ្តាច់ត្រឹមនឹងតែម្តង។

កៈ ហឺ!

ខៈ
វាវេទនាណាស់កាលនៅក្នុងជំនាន់អាពតនឹងហើយពេលដែលបានបែកហើយនឹងវាបានកូនហើយយើងចេះតែរកស៊ីអីនឹងគេនឹងឯងចឹងទៅណា បើយើងនឹងនៅម្នាក់ឯងនឹង។

កៈ
ចាស!ហើយសំរាប់បទពិសោធន៍ល្អៗរបស់លោកយាយវិញតើលោកយាយមានដែលឬទេដូចជារឿងដែលធ្វើអោយលោកយាយបានសប្បាយចិត្តដូចជាពេលដែលលោកយាយបាននឹកឃើញរឿងនឹងមកធ្វើអោយលោកយាយបានសប្បាយចិត្តតើលោកយាយមានដែលឬទេមកដល់សព្វថ្ងៃនឹង?

ខ៖
សព្វថ្ងៃនឹងដែងបានសប្បាយចិត្តបានសប្បាយចិត្តនឹងបានត្រឹមពេលដែលបានមកនៅនឹងវត្តនឹងមកនៅនឹងវត្តនឹងបានប្រហែលជាង១០នឹងនៅក្នុងចិត្តនឹងដូចថាអត់មានខ្វាយខ្វល់អីនោះទេ វាគិតតែតាមនឹងធម៍ព្រះចឹងទៅវាបានធូនៅក្នុងចិត្តនឹងឯងតែគ្រាន់តែសប្បាយចិត្តតែប៉ុណ្ណឹង តែបើថាអោយទៅសប្បាយចិត្តអីនោះធំដុំនឹងវាគ្មានទៅអីនោះទេតែថាវាបានធូ...នឹងនៅក្នុងចិត្តនឹងណា។

ក៖ ចាស!!

ខ៖ វាមិនទៅបានកើតទុក្ខអីនឹងពេកព្រោះអីបានរៀនធម៍ទៅ
រៀនអាអីចឹងទៅអោយអារម្មណ៍នឹងវារាងបានស្ងប់ផងដែលនឹងកុំអោយវានឹងពិបាកចិត្តខ្លាំងពេក។

ក៖ ចាស!

ខ៖ ហើយបើថាអោយសប្បាយអីនឹងវាមិនទាន់មានធំដុំអីនោះទេរឿងសប្បាយនោះនឹង។

ក៖
ចាស!លោកយាយហើយចុះលោកយាយមានបានធ្លាប់បានស្រមៃអីដែលឬទេពេលដែលលោកយាយនៅកាលពីក្មេងនឹងដែលពេលដែលលោកយាយបានធំឡើងតើលោកយាយនឹងបានស្រមៃថានឹងចង់ក្លាយជាអ្វីដែរឬទេពេលដែលលោកយាយធំឡើង?

ខ៖ កាលនឹងយាយបានរៀនបានតិចណាស់កូនអើយយាយបានរៀននឹងត្រឹមតែថ្នាក់ទីនឹង ហើយចឹងក៏មិនមានបានប្រាថ្នានឹងចង់ធ្វើអីនោះដែរព្រោះអីយើងនឹងកាលនឹងវានៅស្រែចឹង ហើយវាមិនបានចេះដឹងអីនោះទេបានត្រឹមតែថាបានចេះដឹងអីនឹងតិចតួចណា
វាមិនបានប្រថ្នាថានឹងចង់បានធ្វើអ្វីនោះថាព្រោះអីខ្ញុំនឹងវាកំសត់មកនឹងហើយបងប្អូនទៀតនឹង វាមានតែ២នាក់ហើយ១ទៀតនឹងបានបែកទៅនឹងក្នុងជំនាន់អាពតនឹង
កាលនៅក្នុងជំនាន់អាពតនឹងដែលគេ
គាត់បានធ្វើជាមេព្រៃនៅឯខេត្តក្រចេះហើយខ្ញុំនឹងណានៅឯស្រុក
ហើយមេព្រៃគេនឹងបានបញ្ជូនមេព្រៃអីនឹងទៅស្រុកអីនឹងចឹងហើយពេលដែលបានបែកអាពតនឹងហើយនឹងគេមិនដឹងថានឹងយកទៅណាវិញអីនឹង

កាលដែលគាត់នៅឯជំនាន់យើងនឹងកាលនៅក្នុងជំនាន់លោកតាសម្ដេចឪនឹងគាត់នឹងដឹងតែគេនឹងយកគាត់នឹងអោយទៅធ្វើជាមេព្រៃគេបានស្រែហៅហើយពេលដែលនៅក្នុងជំនាន់អាពតនឹងគេបានធ្វើការជំលៀសអោយទៅឯណាទៀតចឹងទៅបានបាត់ខ្លួនគាត់ទៀតចឹងទៅកាលនឹងគាត់នឹងមានឆ្នាំខាលចឹងហើយគាត់មានអាយុច្រើនហើយគាត់នឹងនោះ
ហើយបើថាគាត់បាននៅមកដល់ឥឡូវនឹងគាត់នឹងប្រហែលមានអាយុប្រហែលជា៨០ឆ្នាំហើយមិនស្រួលនឹងមានអាយុបាន៩០អីហើយមិនដឹងជាអីនោះទេ
ហឺសឬក៏ប្រហែលជាគាត់នឹងស្លាប់ទៅហើយកាលនឹងព្រោះអីកាលនៅនឹងជំនាន់នឹងអ្នកធ្វើការនឹងគេមិនទៅទុកគាត់អោយបាននៅរស់នោះទេ។

ក៖ ហឺ!!

ខ៖ ច្រើនតែគេយកទៅសំលាប់ចោល។

ក៖ គាត់មានឈ្មោះអ្វីដែលលោកយាយ?

ខ៖ គាត់មានឈ្មោះថា ព្រំ ហឿន។

ក៖ លោកយាយមាននៅសល់ភស្តុតាងដូចជារូបថតនឹងខោអាវអីរបស់គាត់ដែលឬទេ?

ខ៖ អត់ទេអត់មានសោះចាស។

ក៖ ចឹងតើលោកយាយអាចនៅចាំមុខរបស់គាត់ដែលឬទេ?

ខ៖
វាភ្លេចចង់ភ្លេចមុខរបស់គាត់ទៀតនឹងបាត់ទៅទៀតហើយនឹង។ព្រោះអីកាលនឹងគាត់វានៅកំលោះកាលដែលគាត់នៅធ្វើការនឹងរួចដល់ពេលដែលគាត់បានផ្លាស់ទៅនៅឯស្រុកឆ្ងាយចឹងទៅខ្ញុំនេះនឹងក៏មិនបាននឹងធ្វើការទាក់ទងគ្នារហូតមករហូតនឹងរហូតមកទាល់មកនៅក្នុងសម័យពពតនឹងទៀតនឹង។

ក៖ ចាស!ហើយលោកយាយមានបានធ្លាប់បានប្រកាសស្វែងរកបងប្អូនដែលឬទេ?

ខ៖
រកខ្ញុំបានប្រកាសរកខ្ញុំបានរកគាត់ដែលប៉ុន្តែបានទៅតាមនឹងបានទៅតាមរកដល់កន្លែងគាត់

នៅខ្ញុំបានទៅដល់ផ្ទាល់ខ្ញុំបានទៅនឹងកាលនឹងបានទៅរកគាត់២នាក់ជាមួយនឹងតារបស់ខ្ញុំ(ត្រូវជាប្ដីយាយ) ហើយទៅរកគាត់ចឹងទៅក៏បានសួរគេ ហើយមានពូ១នោះគាត់ធ្វើជាប្រធានភូមិសួរទៅគាត់ថាគាត់បានស្គាលមនុស្សនឹងដែលព្រោះអីកាលនឹងគាត់បាននៅជាមួយនឹងគាត់ដែលពេលដែលគេបានផ្លាស់ទៅនឹងគេក៏បានទៅបាត់ទៀតនឹងចឹងហើយគេមិនដឹងថាយកគាត់នឹងទៅដល់ណានោះទេ រកមិនបានឃើញនោះទេគាត់នឹងក៏មិនបានដឹងដែល។ អើកាលនឹងគេបានហៅថាកងៗដូចជាក្រុមចឹងគេហើយយ៉ាង ហើយចឹងគេថាបាននៅជាមួយនឹងគាត់តែឥឡូវនឹងគាត់បានធ្វើជាប្រធានភូមិ នៅក្រចេះនឹងហើយកាលនឹងខ្ញុំនឹងបានទៅរកនៅកន្លែងពូរបស់ខ្ញុំនឹងដែលគាត់នៅនឹង ហើយពេលដែលទៅរកគាត់នៅកន្លែងពូរបស់ខ្ញុំនឹងចឹងទៅគាត់ក៏បានទៅណាបាត់ចឹងដែលទៅ តែមាននៅសល់ប្រធានភូមិគេនឹងនៅចឹងហើយក៏បានសួរគាត់នឹងដែលនៅនឹង។ ហើយតាដែលតានៅនឹងគាត់បានជួបគាត់មែន។តែតាដែលថាបានជួបគាត់នឹងក៏គាត់នឹងចាស់ណាស់ដែលហើយតានឹង។

ក៖ ចាស!

ខ៖ នឹងហើយ

ក៖ បើសិនជាគិតសម័យនឹងទៅប្រហែលជាគាត់មានអាយុប្រហែលជា៨០ឆ្នាំឬក៏៩០ឆ្នាំអីហើយដឹង?

ខ៖ គាត់នឹងពេលដែលខ្ញុំបានទៅជួបនឹងគាត់មានអាយុ៧៧ឆ្នាំតាំងឆ្នាំនឹងហើយនឹងតាំងពីខ្ញុំបានមកនៅនឹងវត្តនឹងមកតាំងមកយូរដែលហើយបានជាខ្ញុំនឹងបានទៅរកគាត់នោះ ដោយសារតែបានលឺដំណឹងហើយពេលបានលឺដំណឹងចឹងទៅក៏បានទៅរកគាត់តាមគេចឹងទៅទៅនឹងក៏បានជួបគេបានប្រទំនាក់ទំនងអីហើយអីចឹងទៅក៏បានទៅជួបនឹងតានឹងដែលគាត់នឹងអាយុរបស់គាត់នឹងក៏...គាត់នឹងបានថាគាត់នឹងមានអាយុ៨០ឆ្នាំហើយគាត់៨២ឆ្នាំហើយអាយុរបស់គាត់នឹងណា។

ក៖ ចាស!

ខ៖
គាត់នឹងធ្លាប់ដែលបានលឺឈ្មោះនឹងដែលនៅក្នុងកងជាមួយនឹងគាត់នឹងតែដល់ពេលដែលបានបែកទៅជាមួយនឹងគាត់នឹងយូរណាស់នឹងបានបែកនឹងមិនបានដឹងថាគេបានយកគាត់នឹងទៅណាវិញនោះទេ ចឹងហើយចឹងបានថារកគាត់វាមិនឃើញមានតែ២នាក់បងប្អូនឹងផង។
ខ្ញុំនឹងគ្មានបានបងនឹងប្អូននឹងគេនោះទេ
មានបងប្អូនប្រុស១នឹងស្រីមួយនឹងមានបងប្អូនតែ២នាក់នឹងទេហើយម្ដាយឪក៏បានស្លាប់ចោលអត់ដែល។

ក៖ ហឺ!ចាស!ហើយដល់ពេលឥឡូវនឹងក៏បានលឺដឹងអស់ហើយលោកយាយណ៎?

ខ៖ នឹងហើយបានឃើញអស់ហើយ។

ក៖ ចាស!លោកយាយ
ចាសលោកយាយចឹងលោកយាយមានពាក្យពេជ្រអ្វីដើម្បីនឹងធ្វើការផ្ដាំផ្ញើរដល់កូនចៅជំនាន់ក្រោយដែលគេបានស្ដាប់សំលេងរបស់លោកយាយដែលឬទេ?

ខ៖ ចាស!ខ្ញុំសូមផ្ដាំផ្ញើរដល់កូនចៅជំនាន់ក្រោយនឹងថា
ពេលដែលនៅក្នុងសម័យពពតនឹងកាលនឹងវាធ្វើបាបរកអីស៊ីមិនបាន
ហើយវាបានធ្វើបាបចឹងដូចដែលខ្ញុំបានរាប់រៀបមកចឹង។
កូនចៅនឹងវាមិនបានដឹងហើយដូចជាកូនរបស់ខ្ញុំនឹងវាក៏មិនបានដឹងដែលថាវានៅយ៉ាងណាដែលនឹងព្រោះអីកាលនឹងវានៅវាងតូចៗដែល
ចឹងហើយផ្ដាំផ្ញើរអីខ្ញុំបានផ្ដាំផ្ញើរដល់និស្សិតដែលគេបានធ្វើការងារសព្វថ្ងៃអីនឹងអោយបានដឹងដែលខ្ញុំបានធ្វើការរាប់រៀបមកនឹងដែលមានប្រវត្តិពីអាពតដែលវាបានធ្វើបាបយើងនឹងឡើងខ្លាំងៗចាស
ហើយចឹងបានថាវាលំបាកសព្វគ្រាប់ណាស់វាបានលំបាកវេទនាហើយអត់បានបាយហូបអត់ឃ្លាន
ធ្វើការងារធន់ណាស់ហើយថាមិនសមនឹងអត់ទោសអោយវានឹងបាននោះទេហើយចឹងបានថាមិនដឹងជានឹងថាអោយវានឹងអាម៉េចទេបើកាលនឹងវានឹងនៅក្នុងកណ្ដាប់ដៃរបស់គេនឹងដែលនឹងណា។

កៈ ចាស!

ខៈ ហើយរឿងអាលំបាកវេទនានឹងវាលំបាកណាស់វាលំបាកហួសនឹងការស្មាន។

កៈ ហឺ!

ខៈ ខ្ញុំធ្វើការរាប់រៀបនឹងវាមិនចង់នឹងកើត។

កៈ ចាស!

ខៈ ចាស!

កៈ ចាស!

ខៈ ចាសម្នាក់ៗនឹងស្ទើនឹងដាច់ជីវិត។

កៈ ចាស!

ខៈ បាននៅនឹងវាវេទនា។

កៈ ចាសលោកយាយហើយទៅលោកយាយមានពាក្យអ្វីសំរាប់នឹងធ្វើការផ្តាំផ្ញើអ្វីទៀតដែលឬទេលោកយាយ?

ខៈ អឺ យាយផ្តាំផ្ញើនឹងដូចដែលយាយបាននិយាយចឹងហើយក្នុងសម័យនឹងហើយកុំអោយជំនាន់ពពតនឹងវាបានចូលមកដូចនៅក្នុងជំនាន់មុននោះទៀត។

កៈ ចាស!

ខៈ វាវេទនាកូននឹងថៅណាស់មិនបានដឹងថាបានទៅណាមកទៅនោះទេវាបានបែកបាត់ព្រត់ប្រាស់គ្នាអស់ហើយ។

កៈ ចាស!

ខ៖ ហើយចឹងទៅវាខំតស៊ូ។

ក៖ ចាស!

ខ៖ តស៊ូនឹងវាមានប្រវត្តិនឹងឡើងដូចត់នឹងវាមានប្រវត្តិវេទនា
វាវេទនានឹងវាវេទនាឡើងសព្វគ្រាប់អស់ទៅហើយចង់ពិណនាវាមិនចេញនោះទេចឹងហើយនឹ
ងវាមិនបានដឹងជាគ្រាប់ជ្រុងជ្រួយនោះទេនាងអើយវាចាស់ណាស់ទៅហើយ។

ក៖ ហឺ!!

ខ៖
និយាយនឹងវាមិនបានទៅគ្រាប់អីនោះទេមានរឿងនៅទៀតហើយវាមានរឿងកើតឡើងនឹងវាក៏
ច្រើន។

ក៖ ចាសចឹងសូមអរគុណច្រើនលោកយាយ។

ខ៖ ចាស!!

ក៖ ចាសា
សូមជូនពរអោយលោកយាយមានសុខភាពល្អនឹងកូនចៅរបស់លោកយាយមានសុភមង្គល
ណាលោកយាយ។

ខ៖ ចាសចៅក៏ចឹងដែលណា។

ក៖ ចាសលោកយាយអរគុណណាលោកយាយ។

ខ៖ ចាសចៅសូមអោយសុខចំរើនចៅទាំង២អោយមានអាយុវែងណាចៅណា។

ក៖ ចាសៗលោកយាយ។